ប្រការ ៨ : សេចក្តីសម្រេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

★ ★ ★

## ៣-លិខិតបញ្ជា

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩

### លិខិតបញ្ជាលេខ ២៣ ល.ប
### ស្តីពីវិធានការទប់ស្កាត់អំពើគេចពន្ធ
### នៅតាមច្រកចេញ-ចូលព្រំដែន

***

**ជូនចំពោះ**

-ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកឧត្តម សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ឯកឧត្តម នាយកអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ

-ឯកឧត្តម អភិបាលខេត្តបន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង តាកែវ កណ្តាល កោះកុង កំពត កំពង់ចាម ព្រៃវែង ក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ពោធិសាត់ សៀមរាប ព្រះវិហារ និងក្រុងព្រះសីហនុ

-ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងប៉ៃលិន និង ក្រុងកែប

-លោកមេបញ្ជាការយោធភូមិភាគទី១ ទី២ ទី៣ ទី៤ និងទី៥

-លោកប្រធានទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ-តំបន់ព្រំដែន និង ទេសភាពី

ក្នុងរយៈពេល ៥ ខែ ដើមឆ្នាំ ១៩៩៩ កន្លងទៅនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា : ចំណូលប្រាក់ពន្ធគយដែលប្រមូលបាន នៅតាមអាត់ច្រកនាំចេញ-នាំចូលទំនិញនៅទូទាំងប្រទេស មានការធ្លាក់ចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងគំរោងចំណូលប្រាក់ពន្ធគយប្រចាំខែ ក្នុងឆ្នាំ ១៩៩៩ នេះ ។ ការធ្លាក់ចុះនូវចំណូលប្រាក់ពន្ធ កណ្តាលមកពីមូលហេតុសំខាន់ៗមួយចំនួន ដូចតទៅ ÷

១-សកម្មភាពនាំចេញ - នាំចូលទំនិញនៅតាមអាត់ច្រកសំខាន់ៗ ជាអាទិ៍ ច្រកនាំចេញ-នាំចូល តាមព្រំដែននៃខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ផែទន្លេស្រុកក្រុងព្រះសីហនុ ខេត្តស្វាយរៀង តាកែវ កណ្តាល ជាពិសេសច្រកប៉ៃលិន បាននិងកំពុងប្រព្រឹត្តទៅជាធម្មតា ពុំមានការធ្លាក់ចុះទេ ។ ប៉ុន្តែសកម្មភាពគេចពន្ធបានកើនឡើងយ៉ាងគគ្រឹកគគ្រេងបំផុត ដែលសុទ្ធតែមានការចូលរួមការពារទំនិញពីសំណាក់ជននិយមខូចមួយចំនួន ។ ដោយឡែកសកម្មភាពគេចពន្ធតាមច្រករបៀងខុសច្បាប់បានកើតឡើងយ៉ាងអនាធិបតេយ្យរាប់សិប

កន្លែង តាមទ្រង់ទ្រាយធំ ដោយដឹកជញ្ជូនតាមរថយន្ត និងតាមទ្រង់ទ្រាយតូច ដោយលីសែង ស្ពាយ រែកផ្ទាល់ខ្លួន ។ ជាទូទៅមុខទំនិញដែលរត់គេចពន្ធទាំងនោះ សុទ្ធសឹងជាមុខទំនិញដែលជាប់អត្រាពន្ធខ្ពស់ ដូចជា ប្រេងឥន្ធនៈ អាគុយ បរិក្ខារអគ្គិសនី ទូរទស្សន៍ គ្រឿងសំអាង ។ល។ និងជាពិសេស នៅច្រកប៉ៃលិន និងច្រកមួយចំនួន នៃខេត្តបន្ទាយមានជ័យ និងបាត់ដំបង មានរថយន្តចង្កូតស្តាំ ដែល ជាទំនិញហាមឃាត់មិនអោយនាំចូលទៀតផង ។

២-កងកំលាំងមានសមត្ថកិច្ចជំនាញ ដែលប្រចាំការនៅច្រកទ្វា មានរជាតិប៉ោយប៉ែត មានចំនួនច្រើននិងផ្ទុយពីការកំណត់ក្នុងលិខិតបញ្ជារបស់រាជរដ្ឋាភិបាលលេខ ២២ ពជ. ខែ កញ្ញា ឆ្នាំ ១៩៩៧ ជាពិសេសគឺកងរាជអាវុធហត្ថលើផ្ទៃប្រទេស និង កងនគរបាលសេដ្ឋកិច្ច ។

៣-សកម្មភាពរត់គេចពន្ធទាំងតាមមាត់ច្រកទ្វារព្រំដែនស្របច្បាប់ និងតាមផ្លូវខុសច្បាប់នានា សុទ្ធតែមានការការពារដោយជនខិលខូចមួយចំនួន ជាហេតុធ្វើអោយសមត្ថកិច្ចមន្ត្រីភ្នាក់ងារគយមិនអាចអនុវត្តភារកិច្ចរបស់ខ្លួន តាមច្បាប់ជាធរមានបានឡើយ ។ លើសពីនេះទៀត នៅតំបន់ប៉ោយប៉ែត មានឃ្លាំងស្តុកទំនិញជាច្រើនកន្លែង ដែលសមត្ថកិច្ចមន្ត្រីភ្នាក់ងារគយជួបការលំបាកក្នុងការចូលទៅធ្វើការត្រួតពិនិត្យ ។

៤-ផ្អែកតាមតួលេខ និងការវាយតម្លៃបានបញ្ជាក់អោយដឹងថា ទំហំទឹកប្រាក់ពន្ធ ដែលបាត់បង់មិនអាចប្រមូលបាននៅតាមមាត់ច្រកទ្វារព្រំដែនប៉ៃលិន ប៉ោយប៉ែត បន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង កណ្តាល ខេត្តតាកែវ និងច្រកផ្សេងៗទៀតមានចំនួនច្រើន គួរអោយកត់សំគាល់ក្នុងមួយខែៗ ។ ក្នុងចំនួនប្រាក់ពន្ធដែលត្រូវបានបាត់បង់នេះ មានមួយចំនួនធំបានបាត់បង់ចំពោះប្រេងឥន្ធនៈ ដែលនាំចូលដោយគេចវេសមិនបង់ពន្ធ ក្រោមការការពារជាប្រចាំពីសំណាក់ជនខិលខូចមួយចំនួនតូច ។

ដើម្បីទប់ស្កាត់ និងឈានទៅលុបបំបាត់សកម្មភាពរត់គេចពន្ធ និងសកម្មភាពអនាធិបតេយ្យទាំងអស់ដែលធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ចំណូលថវិការដ្ឋ ក៏ដូចជាបង្កើនការគ្រប់គ្រងរចនាសម្ព័ន្ធរដ្ឋបាលស៊ីវិល កងយោធពលខេមរភូមិ និងកងនគរបាលជាតិ អោយអនុវត្តការងារត្រឹមត្រូវតាមតួនាទីនិងភារកិច្ច ដែលច្បាប់បានកំណត់ សក្តិសមជាឧបករណ៍ដ៏រឹងមាំ និងមានជំនឿទុកចិត្តពីប្រជារាស្ត្រ និងរាជរដ្ឋាភិបាល ក្នុងការកសាងព្រះរាជាណាចក្រកម្ពុជាមួយជានីតិរដ្ឋ ព្រមទាំងសំដៅបង្កើនចំណូលថវិការដ្ឋ ក្នុងពេលដែលស្ថានភាពថវិការដ្ឋកំពុងជួបការលំបាកនាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាល សូមដាក់ចេញនូវបទបញ្ជា ដូចតទៅ ៖

១-អាជ្ញាធរដែនដីនៃក្រុងប៉ៃលិន ក្រុងព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តតាកែវនិងខេត្តដទៃទៀត ដែលនៅជាប់ព្រំដែនកម្ពុជា ថៃ កម្ពុជា វៀតណាម និងកម្ពុជា ឡាវ និងនៅតំបន់សមុទ្រ កងយោធពលខេមរភូមិ ពិសេសយោធភូមិភាគទី ៥ ទី៤ ទី៣ ទី២ ទី ១ និងកងនគរបាលជាតិ ត្រូវមានវិធានការយ៉ាងសមស្រប ដើម្បីបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពរបស់ជនខិលខូចពាក់ព័ន្ធទៅនឹងការចូលរួមការពារ ឬ ប្រព្រឹត្តអំពីរត់គេចពន្ធខុសច្បាប់ ទោះបីដោយផ្ទាល់ក្តី ឬប្រយោលក្តី ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិនៅគ្រប់អង្គភាព សូមចូលរួមសហការយ៉ាងសកម្មបំផុត និងដោយផ្ទាល់ជាមួយសមត្ថកិច្ចមន្ត្រីភ្នាក់

ងារគយ ក្នុងការទប់ស្កាត់និងបង្ក្រាបអោយមានប្រសិទ្ធភាព នូវរាល់បាតុភាពអនាធិបតេយ្យ ដែលបាននិងកំពុងកើតមាននៅតាមមូលដ្ឋានខេត្ត ក្រុង និងអង្គភាពផ្ទាល់ ។

២-ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋាននគរបាលជាតិ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយសមត្ថកិច្ចមន្ត្រីភ្នាក់ងារគយនៅគ្រប់មូលដ្ឋាន ត្រូវចាត់វិធានការដោយម៉ឺងម៉ាត់បំផុត ចំពោះជនទុច្ចរិតដែលនៅបន្តប្រព្រឹត្តអំពើគេចពន្ធ លើការនាំចូលប្រេងឥន្ធនៈ មុខទំនិញជាប់អត្រាពន្ធខ្ពស់ និងទំនិញហាមឃាត់ផ្សេងៗទៀត ជាពិសេសរថយន្តចង្កូតស្តាំ ។

៣-ចំពោះសកម្មភាពសកម្មរបស់មន្ត្រីភ្នាក់ងារគយ នៅតាមមាត់ច្រកទ្វារនាំចេញ នាំចូលទំនិញទាំងអស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់បំផុត មិនត្រូវបណ្តោយបណ្តែតស៊ីព្រាត ធ្វើអោយជនទុច្ចរិតក្នុងជួរមន្ត្រីភ្នាក់ងារគយ កាន់តែមានល្បិចកេងកិបប្រាក់ពន្ធគយទៀតឡើយ ។

៤-អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ និងអគ្គនាយកដ្ឋាននគរបាលជាតិ ត្រូវដកចេញជាបន្ទាន់នូវកងកម្លាំងប្រដាប់អាវុធ [illegible] នៅច្រកទ្វារព្រំដែនអន្តរជាតិ [illegible] សេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ ។

៥-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តចាត់តាំងគណៈប្រតិភូរបស់ខ្លួនអោយចុះទៅពិនិត្យជាក់ស្តែងស្ថិតស្ថានភាពប្រមូលចំណូលពន្ធគយនៅតាមសាខា និងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនផ្សេងៗទៀតនៅទូទាំងព្រះរាជាណាចក្រ ដើម្បីធានាអោយបាននូវការប្រមូលពន្ធគយ និងអនុវត្តការកិច្ចប្រមូលប្រាក់ពន្ធ អោយដំណើរការបានល្អប្រសើរ សំដៅសំរេចបានលទ្ធផលតាមការគ្រោងទុក និងរាយការណ៍ជាបន្ទាន់ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ជូនប្រមុខរដ្ឋាភិបាល ដើម្បីមានវិធានការទាន់ពេលវេលា ។

៦-ប្រធានទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារទេសភាគ ត្រូវបង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចគ្រប់គ្រងទីស្នាក់ការ និង ត្រូវរាយការណ៍ជាបន្ទាន់អំពីសកម្មភាពលើគ្រប់ផ្នែកការងារក្នុងទីស្នាក់ការមកទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងមហាផ្ទៃ អោយបានទៀងទាត់រៀងរាល់ខែ ។

ផ្អែកតាមលិខិតបញ្ជានេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនៃ អគ្គនាយកដ្ឋាននគរបាលជាតិ ប្រតិភូរាជរដ្ឋាភិបាលប្រធានក្រុងប៉ៃលិន និង ក្រុងកែប អភិបាលខេត្តបន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង កណ្តាល តាកែវ ក្រុងព្រះសីហនុ កំពត កោះកុង និងខេត្តជាប់ព្រំដែនកម្ពុជា ថៃ កម្ពុជា វៀតណាម និងកម្ពុជា ឡាវ និងតំបន់សម្រាប់យោធភូមិភាគទី ១ ទី ២ ទី ៣ ទី ៤ និងទី ៥ ត្រូវសហការគ្នាក្នុងការអនុវត្តន៍លិខិតបញ្ជានេះអោយបានសំរេចលទ្ធផលល្អប្រសើរ សំដៅរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធគយអោយបានច្រើនជាអតិបរមា សំរាប់បង់ចូលថវិការដ្ឋ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា :

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★